# ហេតុអ្វីនយោបាយការបរទេសចិនជាមួយកម្ពុជាលេចធ្លោជាងសហរដ្ឋអាម៉េរិក?

-------------------------------------------------

ដោយៈ **ផាញ់ សារឿន**

ថ្មីៗនេះមានសារព័ត៌មានជាច្រើនបានសរសេរពីទំនាក់ទំនងកម្ពុជាជាមួយសហរដ្ឋអាម៉េរិក ជាពិសេសលើប្រធានបទក្តៅចំពោះការធ្វើដំណើររបស់សម្តេចតេជោ ហ៊ុន សែន ទៅប្រទេសចិន រហូតដល់វិវឌ្ឍនាការពី "មិត្តដែកថែប" ទៅ "មិត្តត្បូងពេជ្រ"។ សព្វថ្ងៃនេះ វិនិយោគិនចិនដែលមកវិនិយោគនៅកម្ពុជាគឺមានសភាពល្អប្រសើរ និងវិនិយោគស្ទើគ្រប់វិស័យដូចជា ការសាងសង់អាកាសយានដ្ឋានធំៗ វិស័យឧស្សាហកម្ម វាយនភ័ណ្ឌកាត់ដេរ វិស័យសំណង់ គ្រឿងអេឡិចត្រូនិច និងអគ្គិសនីជាដើម។ ពេលសម្តេចតេជោ ហ៊ុន សែន ធ្វើដំណើរទៅចិននោះ ភាគីចិនគាំទ្រពេញទំហឹងចំពោះ ១-ការជ្រើសរើសមាគ៌ា អភិវឌ្ឍន៍របស់កម្ពុជា ស្របតាមលក្ខខណ្ឌជាតិរបស់ខ្លួន ២-កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការការពារអធិបតេយ្យ សន្តិសុខ និងផលប្រយោជន៍អភិវឌ្ឍន៍នានា ៣-ការអភិវឌ្ឍបន្តបន្ទាប់ តាមរបៀបវារៈនយោបាយកម្ពុជា និង៤-ប្រឆាំងដាច់ខាតចំពោះការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជា។ កម្ពុជា ១-ប្រកាន់នយោបាយចិនមួយ ២-ប្រឆាំងការជ្រៀតជ្រែកពីខាងក្រៅចូលកិច្ចការផ្ទៃក្នុងរបស់ចិន និង៣-គាំទ្រចិន ការពារផលប្រយោជន៍ស្នូល ព្រមទាំងការបង្រួបបង្រួមជាតិ។ ភាគីទាំងពីរកម្ពុជា-ចិន បានឯកភាពអភិវឌ្ឍក្របខណ្ឌកិច្ចសហប្រតិបត្តិការត្បូងពេជ្រ ផ្តោតសំខាន់លើ នយោបាយ ប្រើប្រាស់តួនាទីរបស់គណៈកម្មាធិការសម្របសម្រួលអន្តររដ្ឋាភិបាលកម្ពុជា-ចិន ឱ្យបានពេញលេញ ពង្រឹងការផ្លាស់ប្តូរអន្តរភាគីគ្រប់កម្រិត ទាំងក្នុងក្របខណ្ឌរដ្ឋ បក្ស និងយុវជន និងបន្តកសាងសហគមន៍វាសនារួមកម្ពុជា-ចិន។ សមត្ថភាពផលិតកម្ម គឺពង្រឹងកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រ និងការបន្សុីគ្នារវាងគំនិតផ្តួចផ្តើមខ្សែក្រវ៉ាត់ និងផ្លូវ និងយុទ្ធសាស្ត្រចតុកោណ។ ទាំងនេះជាហេតុផលបន្ថែមលើភាពលេចធ្លោនយោបាយការបរទេសចិនជាមួយកម្ពុជាជាងសហរដ្ឋអាម៉េរិក។ ហេតុអ្វីបានជានយោបាយការបរទេសចិនលេចធ្លោជាមួយកម្ពុជាជាងសហរដ្ឋអាម៉េរិក?

**នយោបាយការបរទេសចិនបានលេចធ្លោជាងសហរដ្ឋអាម៉េរិកអាចដោយសារសហរដ្ឋអាម៉េរិកយល់ខុសពីកម្ពុជាយ៉ាងតិច៧ចំណុចៈ**

**១.សហរដ្ឋអាម៉េរិកយកការផ្ដល់យោបល់និងការសម្រេចចិត្តពីប្រទេសដែលយល់ឃើញពីទំនាក់ទំនងកម្ពុជា-ចិន។**

នេះជាហេតុផលយល់ខុសពីកម្ពុជាពីព្រោះប្រទេសជិតខាងរបស់កម្ពុជានៅជាប់ជានរឿងប្រវត្តិសាស្រ្ត ដូច្នេះគេមិនឱ្យកម្ពុជារីកចម្រើនជាងខ្លួននោះទេ ហើយចំពោះសម្ព័ន្ធមិត្តដ៏ជិតស្និតរបស់សហរដ្ឋអាម៉េរិកផ្សេងទៀតបានមានទស្សនៈអវិជ្ជមានចំពោះចិនរួចទៅហើយ បើតាមហេតុផលនេះជាការផ្ដល់យោបល់រុញច្រានកម្ពុជាចេញពីផលប្រយោជន៍សហរដ្ឋអាម៉េរិកនិងការទាញយកផលប្រយោជន៍ពីកម្ពុជា។ ជាឧទាហរណ៍ កំពង់ផែទឹកជ្រៅរាម ដែលការសាងសង់មិនមែនតែចិនចូលរួម ថែមទាំងមានជប៉ុនដាក់ខ្លួនចូល ជាពិសេសកំពង់ផែនេះនឹងផ្ដល់ប្រយោជន៍លើការចេញ-ចូលរបស់នាវាដឹកទំនិញធន់ធ្ងន់ម្យ៉ាងវិញទៀតនាវាកងទ័ពជើងទឹកចូលទស្សនកិច្ចកម្ពុជាក៏មិនមែនដើម្បីតែប្រទេសចិននោះទេ ជាក់ស្ដែងនៅឆ្នាំ២០២១នាវាចម្បាំងកងទ័ពជើងទឹកអូស្រ្តាលីចំនួន១គ្រឿងផ្ទុកនាវិកជិត១៦០នាក់ចូល នៅឆ្នាំ២០២២ពីថ្ងៃទី១៨ដល់ថ្ងៃទី២០ ខែវិច្ឆិកា នាវាកងទ័ពជើងទឹកជប៉ុន១គ្រឿងផ្ទុកកងម៉ារីនជាង២០០នាក់ចូលចតនៅកំពង់ផែព្រះសីហនុ ហើយថ្មីៗនេះទៀតសោត ពីថ្ងៃទី១៣-១៧ ខែកុម្ភៈ ឆ្នាំ២០២៣នាវាល្បាតកងទព័ជើងទឹកអង់គ្លេស០១គ្រឿង ចូលចតនៅកំពង់ផែក្រុងព្រះសីហនុ ជាដើម។

**២.សហរដ្ឋអាម៉េរិកចង់មានឥទ្ធិពលលើរាស្រ្តតែមិនរកស៊ីវិនិយោគពាណិជ្ជកម្មជាមួយរាស្រ្តតែបែរជាទុកឱកាសឱ្យប្រទេសចិន។**

ប្រជាជនចិនបានមកធ្វើពាណិជ្ជកម្មជាមួយកម្ពុជា មានការវិនិយោគធំៗដែលនេះជាតម្រូវការរបស់កម្ពុជា។ អាម៉េរិកចង់មានឥទ្ធិពលលើរាស្រ្តគួរតែដាក់ខ្លួនចូលមកកម្ពុជា ដោយបញ្ជូនអ្នកវិនិយោគ ជាពិសេសកម្ពុជាជាទីតាំងស្នូលកណ្ដាលប្រទេសអាស៊ាន ការផលិតនៅកម្ពុជាទាំងអស់មិនត្រឹមតែប្រើប្រាស់នៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែថែមជាចំណុចកណ្ដាលអាចបញ្ជូនទៅបណ្ដាលប្រទេសអាស៊ាន។ ក្រពះជាតម្រូវការជាចាំបាច់ មិនគួរមានតែចិនដាក់ការវិនិយោគនៅកម្ពុជា តែសហរដ្ឋអាម៉េរិកអង្គុយមើលនោះទេ ក្រុមហ៊ុនធំៗរបស់សហរដ្ឋអាម៉េរិកដល់ពេលបង្វែរមកកម្ពុជាហើយ ទាំងនេះជាអ្វីដែលអាម៉េរិកដេកលក់ដោយទុកឱកាសឱ្យចិន។

**៣. ប្រទេសកម្ពុជាស្ដាប់តាមប្រទេសចិនមិនបាច់ខំទាញឬបញ្ចុះបញ្ចូលជាបក្សសម្ព័ន្ធរបស់សហរដ្ឋអាម៉េរិក។**

នេះជាការយល់ខុស ព្រោះសហរដ្ឋអាម៉េរិកនៅតែអាចមានឱកាសធ្វើឱ្យខ្លួនមានឥទ្ធិលពលមកលើកម្ពុជាដោយមិនឱ្យចិនលេចធ្លោតែឯង គឺទីមួយសហរដ្ឋអាម៉េរិកគួរផ្តល់ប្រយោជន៍ដល់កម្ពុជាច្រើនជាងចិន ទីពីរកម្ពុជាមានស្ថិរភាពសន្តិសុខ ស្ថិរភាពនយោបាយដែលអ្នកជំនួញធំៗរបស់សហរដ្ឋអាម៉េរិកវិនិយោគដោយទុកចិត្ត។ ទីបីកម្ពុជាមានឥទ្ធិពលក្នុងបរិបទតំបន់អាស៊ាននិងអន្តរជាតិ ជាក់ស្តែងចូលរួមរបស់កម្ពុជា ជាCo-Sponsor ប្រទេសចូលរួមផ្តួចផ្តើម ឬយល់ព្រមឱ្យគេកត់ត្រាថាជាប្រទេសចូលរួមផ្តួចផ្តើមសេចក្តីព្រាងនៃសេចក្តីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិក្នុងការថ្កោលទោសលើការឈ្លានពានអ៊ុយក្រែនពីសំណាក់រុស្ស៊ីលើប្រទេសអ៊ុយក្រែន។ ទីបួន ប្រជាធិបតេយ្យដែលកម្ពុជាមានគឺជាទិសដៅសមស្របដែលសហរដ្ឋអាម៉េរិកមានស្រាប់រួចទៅហើយ។

## ៤.ប្រទេសផ្សេងចាប់ប្រទេសចិនផងចាប់សហរដ្ឋអាម៉េរិកផងបាន ហេតុអ្វីប្រទេសកម្ពុជាចាប់ដូចគ្នាមិនបាន តែបែរជាតម្រូវជ្រើសរើសចាប់តែមួយណា?

ក្នុងបរិបទអាស៊ានមានប្រទេសថៃទទួលបានប្រយោជន៍ជាច្រើនពីប្រទេសចិនច្រើនជាងកម្ពុជា ប្រទេសវៀតណាមក៏ទទួលបានផលប្រយោជន៍ពីចិនច្រើនជាងកម្ពុជា សិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ហ្វីលីពីន សុទ្ធតែទទួលបានផលប្រយោជន៍ពីចិន។ ខណៈពេលដែលបណ្តាលប្រទេសអាស៊ានមានប្រជាធិបតេយ្យមិនល្អលើសកម្ពុជាដាច់នោះទ។ ជាក់ស្តែងប្រទេសថៃដឹកនាំដោយរដ្ឋប្រហារយោធារហូតដល់១២លើក រហូតដល់ថៃត្រូវបានផ្តល់ចំណាត់ថ្នាក់លេខ១ក្នុងចំណោមប្រទេសនានាលើពិភពលោកដែលធ្វើរដ្ឋប្រហារយោធាញឹកញាប់ជាងគេ។ ចំណែកប្រទេសវៀតណាម និងឡាវកាន់របបនយោបាយបែបសង្គមនិយម ដូចយើងបានដឹងស្រាប់រហូតវៀតណាមបានទាញប្រយោជន៍ពីទំនាក់ទំនងទាំងសហរដ្ឋអាម៉េរិកនិងចិន។ ប្រទេសសិង្ហបុរីកាន់អំណាចផ្តាច់ការមិនគោរពសិទ្ធិមនុស្ស មានឈ្មោះជាលទ្ធិប្រជាធិបតេយ្យតែនៅលើក្រដាស នឹងមិនសូវមានសិទ្ធិសេរីភាពខាងបញ្ចេញមតិប៉ុន្មានឡើយ។ សិង្ហបុរី ជាប់លេខខ្សោយណាស់ខាងសេរីភាពសារព័ត៌មាន ពោលគឺជាប់ចំណាត់ថ្នាក់លេខ១៥១ ក្នុងចំណោមប្រទេស១៨១លើលោក។ ចំណែកហ្វីលីពីនប្រជាធិបតេយ្យផុសស្រួល។ ប្រជាធិបតេយ្យប្រទេសមីយ៉ាន់កាន់តែធ្លាក់ចុះខ្លាំង។ល។ តើអ្វីជាភាពប្រាកដនយោបាយការបរទេសជាមួយប្រទេសប្រជាធិបតេយ្យ?

## ៥.វប្បធម៌ប្រទេសចិនបានចាក់គ្រឹះរឹងមាំដែលនាំឱ្យប្រទេសកម្ពុជាស្រលាញ់ឆោងចាប់យកប្រទេសចិន។

នេះជាការយល់ខុស ព្រោះវប្បធម៌ចិនចាក់គ្រឹះប្រទេសនៅប្រទេសដទៃច្រើនជាងកម្ពុជា ដូចជាប្រទេសថៃដែលមានប្រវត្តិកើតចេញពីខេត្តចិន ចំណែកទំនៀមទម្លាប់វៀតណាមស្ទើរតែទាំងដូចទំនៀម

ទម្លាប់ប្រទេសជនជាតិចិន។ បើយោងតាមគេហទំព័រ encyclopedia ដែលផ្សាយការស្រាវជ្រាវលើប្រធានបទ Chinese in Southeast Asia បានបង្ហាញថាប្រជាជនចិនភាគច្រើនលើសលប់នៅអាស៊ីអាគ្នេយ៍គឺប្រទេសសិង្ហបុរី ដែលមានប្រជាជនចិនប្រមាណ ២លាននាក់ ស្មើនឹង៧៦ ភាគរយនៃចំនួនប្រជាជន៣លាននាក់។ នៅប្រទេសម៉ាឡេស៊ី ជនជាតិចិនបង្កើតជាជនជាតិភាគតិចដ៏ធំមួយ ដែលបច្ចុប្បន្នត្រូវបានប៉ាន់ប្រមាណថាមានចំនួន៣៤ភាគរយនៃចំនួនប្រជាជន១៨លាននាក់។ នៅប្រទេសឥណ្ឌូណេស៊ីដែលជនជាតិចិនមានត្រឹមតែ៣ភាគរយនៃចំនួនប្រជាជនសរុប១៩៥លាននាក់ មានជនជាតិចិនពី៥ទៅ៦លាននាក់។ នៅក្នុងប្រទេសថៃ ប្រជាជនចិនត្រូវបានគេប៉ាន់ប្រមាណថាពី ៥ទៅ៦ លាននាក់ ឬច្រើនជាងនេះក្នុងចំណោមចំនួនប្រជាជនសរុប៥៧លាននាក់។ នៅក្នុងប្រទេសហ្វីលីពីនមានប្រជាជនចិនចំនួន៦០ម៉ឺននាក់ក្នុងចំនួនចំណោមប្រជាជនចំនួន៦២ម៉ឺនលាននាក់។ នៅកម្ពុជាមាន៣០ម៉ឺននាក់ក្នុងចំណោមចំនួនប្រជាជន៨,៥លាននាក់។ នៅប្រទេសឡាវ២៥ម៉ឺននាក់ក្នុងចំនួនប្រជាជន៤លាននាក់។ នៅវៀតណាមនៅពាក់កណ្តាលទសវត្សរ៍ទី៧០មានជនជាតិចិនចំនួន២លាននាក់ប៉ុន្តែមានមនុស្សជាច្រើនបានក្លាយជាជនភៀសខ្លួន។

## ៦.ប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយប្រទេសចិនព្រោះចង់បានប្រយោជន៍សេដ្ឋកិច្ចពីប្រទេសចិន និងការពារអំណាចដោយមានចិនជួយគាំទ្រ។

នេះជាការយល់ខុស តាមការពិតកម្ពុជាបានដើរផ្លូវនយោបាយការបរទេសចម្រុះពណ៌ ដោយកម្ពុជាមិនមែនមានតែមានទំនាក់ទំនងតែប្រទេសមួយឬដើម្បីតែប្រទេសមួយនោះទេ។ កម្ពុជាត្រូវការផលប្រយោជន៍ហើយបរទេសក៏ត្រូវការ សម្រាប់កម្ពុជាជាផលប្រយោជន៍ដែលមិនធ្វើឱ្យបាត់បង់អធិតេយ្យភាពជាតិ និងបូរណភាពទឹកដី ការមិនជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសនានា។ អំណាចដែលកម្ពុជាត្រូវការគឺអំណាចជីវភាពពលរដ្ឋ អំណាចភាពរីកចម្រើនរបស់កម្ពុជា អំណាចនៅលើឆាកអន្តរជាតិ អំណាចស្ថេរភាពសន្តិសុខជាតិនិងវិបុលភាព អំណាចមិនមានការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់កម្ពុជា អំណាចប្រជាធិបតេយ្យពិតប្រាកដ អំណាចស្របតាមរដ្ឋធម្មនុញ្ញរបស់កម្ពុជា។ ចំណែកការពឹងតែប្រទេសចិន ត្រូវការតែប្រទេសចិនជាគំនិតមនោគមន៍វិទ្យាហួសសម័យ។

## ៧.ប្រទេសកម្ពុជាមានទំនាក់ទំនងជាមួយប្រទេសចិន ព្រោះប្រទេសចិនបានប្រាប់វិធីទប់ទល់សហរដ្ឋអាមេរិក។

នេះជាហេតុផលមិនពិតព្រោះកម្ពុជាមិនចាប់ទុកភាគីណាមួយជាសត្រូវនោះទេ។ ការធ្វើដំណើរទៅប្រទេសចិនរបស់កម្ពុជាគឺដើម្បីជីវភាពរបស់ប្រជាពលរដ្ឋ ដើម្បីទទួលបានហេដ្ឋារចនាសម្ព័ន្ធប្រណិត

ផ្លូវ អគារ រថភ្លើងល្បឿនលឿន ការបណ្ដុះបណ្ដាលធនធានមនុស្ស ដំណើរទេសចរណ៍បរទេស សមត្ថភាពផលិតកម្មកសិកម្ម និងការកែច្នៃផលិតផលកសិកម្ម បច្ចេកវិទ្យា ជំនួយ ថាមពល សន្តិសុខ ដើម្បីទទួលបានការវិនិយោគ និងដើម្បីភាពរីកចម្រើនរបស់កម្ពុជា។ល។

ទាំងនេះនៅមិនទាន់គិតពីដំណើរការកិច្ចសហប្រតិបត្តិរបស់កម្ពុជាជាមួយសហរដ្ឋអាម៉េរិកដែលលេចធ្លោគឺត្រូវប្រធានាធិបតីសហរដ្ឋអាម៉េរិកឈានជើងចូលទឹកដីកម្ពុជាដែលមិនមែនមកកម្ពុជាត្រឹមកម្រិតអាស៊ានទេ តែមកក្នុងកម្រិតទំនាក់ទំនងកិច្ចសហប្រតិបត្តិការទ្វេភាគី។

សរុបសេចក្ដីមកភាពលេចធ្លោនៅក្នុងទំនាក់ទំនងនយោបាយការបរទេសចិនជាមួយកម្ពុជាជាងសហរដ្ឋអាម៉េរិកគឺដោយសារសហរដ្ឋអាម៉េរិកអាចយល់ខុសទាំង៧ចំណុចខាងលើនេះ។ សហរដ្ឋអាម៉េរិកមានឥទ្ធិពលលេចធ្លោនៅកម្ពុជា តែនឹងផ្ដល់ឱកាសឱ្យចិនបន្តទៀតនៅពេលដែលសហរដ្ឋអាម៉េរិកបន្តយល់ខុសពីកម្ពុជា។ ភាពយល់ខុសរបស់អាម៉េរិមចំពោះកម្ពុជាជាចំណែកលក្ខខណ្ឌចែកឥទ្ធិពលនិងការបន្ថយឥទ្ធិពលអាម៉េរិក។ ចង់ឬមិនចង់កម្ពុជាជាទីតាំងភូមិសាស្ត្រនយោបាយដ៏សំខាន់ដែលប្រទេសចិននិងអាម៉េរិកមិនអាចខ្វះកម្ពុជា ហើយចិននឹងបន្តភាពលេចធ្លោនៅកម្ពុជា នៅពេលកម្ពុជាខិតខំអុំទូកតែសហរដ្ឋអាម៉េរិកបែរជាយកជើងរាទឹកហើយអង្គុយចាំទទួលផល៕